# II- អនុក្រឹត្យ

## អនុក្រឹត្យលេខ ០១/អនក្រ.បក

## ស្តីពីការបដិសេធមិនទទួលស្គាល់សិទ្ធិរបស់តំណាងសាលាខេត្តសៀមរាប ក្នុងការងារចុះកិច្ចសន្យាជួលសណ្ឋាគារវីឡាអប្សរា

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

  បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

  បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រម នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- បទបញ្ជាលេខ ៣០/បប ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់រាជរដ្ឋាភិបាល
- យោងការខ្វះលក្ខណៈសម្បត្តិគតិយុត្តក្នុងសមត្ថកិច្ចចុះហត្ថលេខាតំណាងឲ្យសាលាខេត្តសៀមរាប
- យោងតាមការអនុវត្តន៍គោលការណ៍រដ្ឋបាលទូទៅ

### សំរេច

**មាត្រា ១.-** បដិសេធមិនទទួលស្គាល់សិទ្ធិរបស់លោក ជា ភក្តី តំណាងសាលាខេត្តសៀមរាបក្នុងការងារចុះកិច្ចសន្យាជួលសណ្ឋាគារវីឡាអប្សរា ធ្វើនៅខេត្តសៀមរាប ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ ដោយមូលហេតុ ពុំមានលក្ខណៈសម្បត្តិគតិយុត្តក្នុងសមត្ថកិច្ចនិងមិនស្របទៅនឹងបទបញ្ជាស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

មាត្រា ២ ._ ចាត់ទុកជាមោឃៈនូវសិទ្ធិនិងលិខិតបញ្ញត្តិទាំងឡាយ ដែលមានចែងនៅក្នុងកិច្ចសន្យាជួលរវាងលោក ជា វណ្ណី ជាម្ចាស់ក្រុមហ៊ុនវិទ្យុអប្សរាមេឌីជីត ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៩ ដែលនាំឲ្យកិច្ចសន្យាជួលនេះ គ្មានសុពលភាព ។

មាត្រា ៣._ ប្រគល់ការគ្រប់គ្រងសណ្ឋាគារអប្សរា ដែលមានទីតាំងនៅខាងកើតមហាសណ្ឋាគារអង្គរ លើផ្ទៃដីចំនួន ៥.៧៩៧ ម៉ែត្រក្រឡា ឲ្យអាជ្ញាធរអប្សរា និងអាជ្ញាធរខេត្តសៀមរាប ។

មាត្រា ៤._ រាជរដ្ឋាភិបាលមិនទទួលខុសត្រូវលើការខូចខាតណាមួយ ដែលមិនស្របនឹងនីតិវិធីស្តីពីការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ។

មាត្រា ៥._ រាល់បទបញ្ញត្តិទាំងឡាយដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៦._ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ អាជ្ញាធរអប្សរា អភិបាលខេត្តសៀមរាប ក្រុមហ៊ុនវិទ្យុអប្សរាមេឌីជីត និងគ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធត្រូវអនុវត្តអនុក្រឹត្យនេះឲ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី០៥ ខែមករា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

***

## អនុក្រឹត្យលេខ ០២/អនក្រ.បក

## ស្តីពីការលុបចោលដីកាលេខ ១៤១ សសរ. ចុះថ្ងៃទី២៧ ខែតុលា ឆ្នាំ១៩៩៥ របស់សាលាខេត្តសៀមរាប

***

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី